
សេចក្តីណែនាំ

អង្គការឈរអ៊ូសាន
សម្រាប់កុមារ



ChorogUsan
for children | CAMBODIA

តើអង្គការឈរអ៊ូសានជានរណា?

ChorogUsan
for children

នៅក្នុងភាសាកូរ៉េ **“Chorog ឈរ”** មានន័យថា **“ពណ៌បៃតង”** ដែលតំណាងឱ្យ ភាពរស់រវើក
ចំណែកឯ **“Usan អ៊ូសាន”** មានន័យថា **“ឆត្រ”** ដែលតំណាងឱ្យ ការការពារ និងក្តីស្រមៃ។

ដងឆត្រ តំណាងឱ្យសសរទ្រូងដ៏រឹងមាំសម្រាប់កុមារ។

ជារួម និមិត្តសញ្ញា(Logo) ChorogUsan ឈរអ៊ូសាន ឆ្លុះបញ្ចាំងពីអត្តសញ្ញាណរបស់យើង
ដោយធានាថាកុមារទាំងអស់អាចមានភាពរីករាយនៅក្រោមឆត្របៃតងដែលយើងផ្តល់ជូន។

ចក្ខុវិស័យ

បង្កើតពិភពលោកមួយដែលកុមារមានភាពរីករាយ

បេសកកម្ម

អង្គការដែលធ្វើឱ្យកុមារទទួលបានសុភមង្គល

ពាក្យស្លោក

តែងតែនៅជាមួយកុមារជានិច្ច

អាទិភាពលើកុមារ

យើងគិតគូរពីឧត្តមប្រយោជន៍របស់កុមារជាចម្បងនៅក្នុងគ្រប់ទិដ្ឋភាពនៃកម្មវិធីរបស់យើង

សុចរិតភាព

យើងកសាងទំនុកចិត្តតាមរយៈការធ្វើការដោយមានតម្លាភាពនិងគណនេយ្យភាពប្រកបដោយភាពសុចរិត

ជំនាញ

យើងប្រកាសខ្លួនជាអ្នកស្វែងរកមតិគាំទ្រប្រកបដោយវិជ្ជាជីវៈដើម្បីកុមារ និងលើកកម្ពស់សិទ្ធិរបស់ពួកគេ

ស្មារតីការងារ

យើងដើរតួនាទីជាអ្នកដឹកនាំក្នុងការស្វែងរកនិងដោះស្រាយបញ្ហាប្រឈមនានានៅក្នុងសង្គមរបស់យើង

ចក្ខុវិស័យឆ្ពោះទៅកាន់២០៣០



នៅឆ្នាំ២០៣០ ពួកយើងនឹងបង្កើតពិភពលោកមួយដែលកុមារគ្រប់រូបទទួលបានឱកាសដើម្បីរីកចម្រើន និងសម្រេចក្តីស្រមៃរបស់ពួកគេ។

ផលជះសម្រាប់កុមារ

មិនថាពួកគេកើត និងរស់នៅទីណាក៏ដោយ កុមារគ្រប់រូបអាចលូតលាស់ ដោយមានសុខភាពល្អ និងមានភាពអង់អាច។

ផលជះសម្រាប់ពិភពលោក

កុមារអាចរស់នៅក្នុងពិភពលោកមួយដែលផ្តោតការយកចិត្តទុកដាក់ជាចំបង និងគិតគូរទៅលើឧត្តមប្រយោជន៍កុមារ។

បញ្ហាចម្បងទាំង៥	ការផ្លាស់ប្តូរសម្រាប់កុមារ	ផលជះសម្រាប់ពិភពលោក
ការថែទាំ និងការអភិវឌ្ឍ	**កុមារអភិវឌ្ឍនៅក្នុងបរិយាកាសប្រកបដោយការយកចិត្តទុកដាក់** កុមារកើតមកដោយសុវត្ថិភាព និងលូតលាស់ប្រកបដោយសុខភាពល្អ ដោយមានការគាំទ្រដោយប្រព័ន្ធកិច្ចការពារកុមារដ៏រឹងមាំ។	ធានាថាសហគមន៍និងបរិយាកាសជុំវិញកុមារ ពោរពេញទៅដោយកុមារមេត្រីភាព។
សុវត្ថិភាពពីអំពើហិង្សា	**កុមារត្រូវបានការពារនៅគ្រប់កន្លែង និងគ្រប់បរិយាកាស** មិនថានៅលើប្រព័ន្ធអ៊ីនធឺណិត អនឡាញ ឬខាងក្រៅ នៅផ្ទះ នៅសាលារៀន និងក្នុងសហគមន៍របស់ពួកគេនោះទេ កុមារត្រូវប្រាកដទទួលបានសុវត្ថិភាពគ្រប់ទីកន្លែង។	
ការអប់រំ និងការអភិវឌ្ឍ	**កុមារទទួលបានការអប់រំដោយមិនមានទាំងឧបសគ្គនានា និងអាចបន្តក្តីស្រមៃរបស់ពួកគេបាន** ពួកគេអាចបន្តការសិក្សានូវអ្វីដែលពួកគេចង់ស្វែងយល់ដោយគ្មានឧបសគ្គរាំងដូចជាបញ្ហាហិរញ្ញវត្ថុ ដែលជំរុញដល់សក្តានុពលពេញលេញរបស់ពួកគេ។	សម្លេងរបស់កុមារត្រូវបានស្តាប់ ផ្តល់តម្លៃ និងការគោរពយ៉ាងពេញលេញ។
សុខភាព និងសុខុមាលភាព	**កុមារមានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត** នៅពេលពួកគេមានសុខុមាលភាពទាំងផ្លូវកាយ ផ្លូវចិត្ត និងសង្គម នោះពួកគេនឹងអាចបញ្ចេញមតិ និងរស់នៅប្រកបដោយសេរីភាព។	មនុស្សកាន់តែច្រើនចូលរួមក្នុងការដោះស្រាយបញ្ហាដែលប៉ះពាល់ដល់កុមារ។
ឯករាជ្យភាព និងការរស់នៅដោយខ្លួនឯង	**កុមារទទួលបានភាពជាម្ចាស់ការលើជីវិតខ្លួនឯង** ពួកគេសម្រេចបាននូវឯករាជ្យភាពផ្នែកសេដ្ឋកិច្ច ផ្លូវចិត្ត និងសង្គម ដោយមានសមត្ថភាពកំណត់វិថីជីវិតរបស់ពួកគេប្រកបដោយទំនុកចិត្ត។	

ចក្ខុវិស័យឆ្ពោះទៅកាន់ឆ្នាំ២០៣០

៣០៧ លានដុល្លារ

ថវិកាសរុបដែលត្រូវបានកៀរគរដើម្បីដោះស្រាយបញ្ហាសង្គម៣ក៏ព័ន្ធនឹងកុមារនៅប្រទេសកូរ៉េ និងជុំវិញពិភពលោក

៤.៦១ លាននាក់

ចំនួនកុមារដែលជីវិតរបស់ពួកគេត្រូវបានផ្លាស់ប្តូរដោយវិជ្ជមានក្រោមការអនុវត្តកម្មវិធីរបស់យើង

១៧ ករណី

ចំនួនគោលនយោបាយ ឬប្រព័ន្ធដែលអង្គការមានឥទ្ធិពល និងចូលរួមស្វែងរកមតិគាំទ្រសម្រាប់ការកែប្រែ ឬធ្វើឱ្យប្រសើរ

អ្នកគាំទ្រ ១លាននាក់

ចំនួន “អ្នកគាំទ្របៃតងឆ្ពើម” ចូលរួមបរិច្ចាគដើម្បីសុភមង្គលសម្រាប់កុមារ

ចំណាត់ថ្នាក់ លេខ១

មានការទទួលស្គាល់អង្គការឈរអ៊ូសានសម្រាប់កុមារ ជាអង្គការឈានមុខគេលេខ១ក្នុងការធ្វើការដើម្បីសុខុមាលភាពសង្គម

១៧០០ ស្ថាប័ន

ចំនួនអង្គការដៃគូកំពុងធ្វើការជាមួយអង្គការឈរអ៊ូសានដើម្បីដោះស្រាយបញ្ហាប្រឈមនានារបស់កុមារ

អនាគតមួយដែលបង្កើតដោយអង្គការឈរអ៊ូសានសម្រាប់កុមារ

ពិភពលោកមួយដែលកុមារគ្រប់រូបទទួលបានឱកាសដើម្បីរីកចម្រើន និងសម្រេចក្តីសុបិន្តរបស់ពួកគេ

ដំណើររបស់យើង

១៩៤៨

អង្គការឈរអ៊ូសានសម្រាប់កុមារ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៤៨ ក្នុងអំឡុងពេលសង្គ្រាមកូរ៉េ ដោយចាប់ផ្តើមជាការិយាល័យប្រចាំប្រទេសកូរ៉េរបស់អង្គការមូលនិធិកុមារគ្រិស្តសាសនា Christian Children's Fund(CCF)។

១៩៨៦

យើងបានបំបែកខ្លួនជាស្ថាប័នពេញសិទ្ធិ ដោយផ្លាស់ប្តូរពីអ្នកទទួលជំនួយ ទៅជាអង្គការម្ចាស់ជំនួយវិញ។ ចាប់តាំងពីពេលនោះមក យើងបានក្លាយជាស្ថាប័នដឹកនាំឈានមុខគេក្នុងកិច្ចការពារកុមារនៅប្រទេសកូរ៉េ និងសាយតាយប្រតិបត្តិការរបស់យើងនៅប្រទេសផ្សេងៗទៀតជុំវិញពិភពលោក។

វត្តមានអង្គការឈរអ៊ូសាន នៅប្រទេសកម្ពុជា

១៩៩៦

យើងបានចាប់ផ្តើមទំនាក់ទំនងជាមួយប្រទេសកម្ពុជាតាមរយៈ ចលនាមូលដ្ឋានរបស់ប្រជាជនកូរ៉េ ដែលបានបរិច្ចាគសម្លៀកបំពាក់និងថវិកាដើម្បីជួយកុមារដែលរងផលប៉ះពាល់ដោយសង្គ្រាមស៊ីវិលនៅកម្ពុជា។

១៩៩៦-២០២៣

ពួកយើងអនុវត្តគម្រោងអភិវឌ្ឍន៍ផ្សេងៗតាមរយៈអង្គការដៃគូក្នុងស្រុក។

២០២៤

ការិយាល័យឈរអ៊ូសានប្រចាំប្រទេសកម្ពុជា ត្រូវបានបង្កើតឡើង និងអនុម័តជាផ្លូវការ ដើម្បីដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីដោយផ្ទាល់។



វត្តមានជុំវិញពិភពលោក



យើងកំពុងមានប្រតិបត្តិការចំនួន ៣៩ ទីតាំងក្នុងប្រទេសកូរ៉េ

- **ទីស្នាក់ការកណ្តាលប្រចាំតំបន់៖** ១ទីតាំង
- **មជ្ឈមណ្ឌលសុខុមាលភាពសង្គម៖** ៧ទីតាំង
- **មជ្ឈមណ្ឌលថែទាំកុមារក្នុងគ្រួសារធម៌៖** ៦ទីតាំង
- **ទីភ្នាក់ងារជំនាញផ្នែកកិច្ចការពារកុមារ៖** ៤ទីតាំង
- **សហគមន៍ហានសារាំង៖** ៣ទីតាំង
- **មជ្ឈមណ្ឌលកុមារស៊ីហឹមថាអូលលីម៖** ១ទីតាំង

★ ការិយាល័យប្រចាំប្រទេសមានក្នុង៤ប្រទេស

អាស៊ី៖
៣ប្រទេស រួមមានប្រទេសកម្ពុជា វៀតណាម និងហ្វីលីពីន

អាហ្វ្រិច៖
១ប្រទេស គឺប្រទេសរវ៉ាន់ដា

កម្មវិធីគាំទ្រនៅក្នុង ២៧ប្រទេស ជុំវិញពិភពលោក

អាហ្វ្រិច៖
១៣ប្រទេស រួមទាំងប្រទេសរវ៉ាន់ដា និងតង់ហ្សានី

មជ្ឈិមបូព៌៖
២ប្រទេស រួមទាំងប្រទេសអ៊ុយក្រែន និងប៉ាឡេស្ទីន

អាស៊ី៖
១១ប្រទេស រួមទាំងប្រទេសមីយ៉ាន់ម៉ា និងម៉ុងហ្គោលី

អាមេរិកកណ្តាល និងខាងត្បូង៖
១ប្រទេស គឺប្រទេសប៉ារ៉ាហ្គាយ

វិស័យគម្រោងកម្មវិធី

ការអភិវឌ្ឍ



ការអប់រំ

ការទទួលបានបរិយាកាសសិក្សាប្រកបដោយគុណភាព

សាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំដែលសមស្របតាមវ័យ និងផ្តល់ធនធានអប់រំដ៏សម្បូរបែបសម្រាប់កុមារទាំងអស់ដើម្បីពង្រីកឱកាសសិក្សាដោយសមភាព។



កិច្ចការពារកុមារ

ការទទួលបានកន្លែងសុវត្ថិភាព

លើកកម្ពស់ស្ថិរភាពផ្លូវចិត្ត ដោយការពង្រឹងប្រព័ន្ធកិច្ចការពារ និងការឆ្លើយតប ដើម្បីរក្សាសុវត្ថិភាពពួកគេពីការរំលោភបំពាន និងអំពើហិង្សានានា។



ជំនួយមនុស្សធម៌

ការទទួលបានជំនួយសង្គ្រោះជីវិត

ផ្តល់ជំនួយបន្ទាន់ដូចជាអាហារ ការថែទាំសុខភាព និងការរស់នៅមានសុវត្ថិភាពដល់កុមារ អាណាព្យាបាល និងសមាជិកសហគមន៍នានាអំឡុងពេលប្រទេសស្ថិតក្នុងសង្គ្រាម វិបត្តិនានា។

ការផ្តល់អំណាច

ចំនួនអ្នកចូលរួមគម្រោង
៣៣៨ ៦៤២ នាក់

ពង្រឹងការចូលរួមរបស់សហគមន៍

ជួយកុមារ និងសមាជិកសហគមន៍ឱ្យយល់ពីសារៈសំខាន់នៃការអប់រំ ព្រមទាំងជំរុញការចូលរួមរបស់សហគមន៍ និងរដ្ឋាភិបាលដើម្បីគាំទ្រការអប់រំប្រកបដោយនិរន្តរភាព។

ចំនួនប្រទេសទទួលបានការគាំទ្រ
១៦ ប្រទេស

សិទ្ធិទទួលបានការអប់រំ

កែលម្អគុណភាពនៃការអប់រំ ដោយលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលបានការអប់រំរបស់កុមារ និងការស្វែងរកមិតគាំទ្រសម្រាប់គោលនយោបាយអប់រំឱ្យមានភាពរឹងមាំជាងមុន ដោយធ្វើការជាមួយរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិ។

ការស្វែងរកមតិគាំទ្រ

ចំនួនអ្នកចូលរួមគម្រោង
១៩៩ ៥២៧ នាក់

កសាងសមត្ថភាពផ្នែកការពារកុមារ

ផ្តល់ការអប់រំស្តីពីកិច្ចការពារកុមារដល់កុមារ អាណាព្យាបាល ដើម្បីពង្រឹងជំនាញការពារខ្លួន ព្រមទាំងលើកកម្ពស់ការទទួលខុសត្រូវរួមសម្រាប់ការពារកុមារ តាមរយៈកិច្ចសហការជាមួយសហគមន៍ និងរដ្ឋាភិបាល។

ចំនួនប្រទេសទទួលបានការគាំទ្រ
៦ ប្រទេស

សិទ្ធិទទួលបានកិច្ចការពារ

លើកកម្ពស់ការយល់ដឹងក្នុងសង្គមអំពីការការពារកុមារ ជំរុញឱ្យមានការគោរពសិទ្ធិកុមារ និងការស្វែងរកមតិគាំទ្រឱ្យគោលនយោបាយការពារកុមារមានភាពរឹងមាំជាងមុន ជាមួយរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ។

ចំនួនអ្នកចូលរួមគម្រោង
៥០០ ៩៩០ នាក់

កសាងភាពធន់ដើម្បីដោះស្រាយវិបត្តិនានា

អប់រំសហគមន៍ និងមន្ត្រីរដ្ឋាភិបាលស្តីពីជំនួយមនុស្សធម៌ និងការការពារកុមារ ដើម្បីពង្រឹងសមត្ថភាពឆ្លើយតបនឹងវិបត្តិឱ្យបានទាន់ពេល។

ចំនួនប្រទេសទទួលបានការគាំទ្រ
៧ ប្រទេស

សិទ្ធិរស់រានមានជីវិត

លើកកម្ពស់ការចូលរួមរបស់សហគមន៍ និងកៀរគរការគាំទ្រមនុស្សធម៌អន្តរជាតិ ដើម្បីធានាថាកុមារទទួលបានការការពារជាអាទិភាពក្នុងអំឡុងពេលវិបត្តិ។

សេចក្តីណែនាំស្តីពីតុក្កតា

Cho Mung E ឆូម៉ុងអ៊ី

នៅពេលណាដែលកុមារត្រូវការជំនួយ ឬចង់និយាយអ្វីឱ្យគេស្តាប់ ច្រមុះពណ៌បៃតង របស់ ឆូម៉ុងអ៊ី នឹងចាប់ផ្តើមបញ្ចេញពន្លឺ។

ដោយហោះហើរជាមួយឆត្រវេទមន្ត ពណ៌បៃតង ឆូម៉ុងអ៊ី ហោះមកជួបកុមារ ដោយបើកផ្លូវឱ្យមានពណ៌បៃតង ដើម្បីបញ្ជាក់ពីការនាំមកនូវក្តីសង្ឃឹម និងក្តីស្រមៃថ្មីមួយ អាចជួយកុមារឱ្យអភិវឌ្ឍបាន។



ឆត្រវេទមន្ត ពណ៌បៃតង អាចប្រែរូបរាង និងហោះហើរបានដោយធ្វើដំណើរពេញផ្ទៃប្រទេស និងពិភពលោកដើម្បីទៅជួបកុមារដែលត្រូវការជំនួយ

ត្រចៀកដ៏កក់ក្តៅ និងទន់ភ្លន់ដែលអាចស្តាប់យ៉ាងយកចិត្តទុកដាក់នូវកង្វល់ និងរឿងរ៉ាវរបស់កុមារ

ស្នាមញញឹមដ៏ធំ និងរូសរាយរាក់ទាក់ ដែលបង្ហាញពីភាពកក់ក្តៅ និងការយល់ចិត្តដល់កុមារ

ខ្លួនពណ៌ស ដែលតំណាងឱ្យបេះដូងដ៏បរិសុទ្ធ ដែលផ្តល់ការយកចិត្តទុកដាក់លើកុមារ

ច្រមុះពណ៌បៃតងដែលមានវេទមន្តពិសេស ជួយហិតស្វែងរកកុមារដែលត្រូវការជំនួយ ឬចង់និយាយប្រាប់ពីបញ្ហារបស់ពួកគេ

រាងកាយ និងជើងដ៏រឹងមាំ ដែលការពារកុមារ មិនថាស្ថិតក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ

ទំនាក់ទំនង

អាសយដ្ឋាន៖ ជាន់ទី៧ អគារ Amass Central Tower ផ្ទះលេខ៧៦ ផ្លូវ៦៣ បឹងកេងកងទី១ រាជធានីភ្នំពេញ
ទូរស័ព្ទទំនាក់ទំនង៖ +855 (0)23 902 105
គេហទំព័រ៖ www.chorogusan.org.kh